**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ : ៥១៧៦៧/២៣ មស.ភាព

## សូមគោរពជូន
## សម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី នៃក្រសួង ស្ថាប័ន
## ឯកឧត្ដម លោកជំទាវ អភិបាលនៃគណៈអភិបាល រាជធានី ខេត្ត
## លោក លោកស្រី អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ

**កម្មវត្ថុ ៖** ស្ដីពីការគ្រប់គ្រងការផ្ទេរនិងផ្លាស់ប្ដូរការងាររបស់មន្ត្រីរាជការស៊ីវិល។

**យោង ៖**- ប្រសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់នាថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៣ របស់**សម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** ស្ដីពីការផ្អាកការផ្ទេរនិងផ្លាស់ប្ដូរការងាររបស់មន្ត្រីរាជការស៊ីវិល
- ចំណារឯកភាពដ៏ខ្ពង់ខ្ពស់ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣ របស់**សម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** លើលិខិតរបស់ក្រសួងមុខងារសាធារណៈ លេខ៥១៧២/២៣ មស.របក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៣។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **សម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី នៃក្រសួង ស្ថាប័ន ឯកឧត្ដម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត លោក លោកស្រី អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ** មេត្ដាជ្រាបថា ផ្អែកលើការសម្រេចរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងស្ថានភាពបំពេញការងាររបស់មន្ត្រីរាជការស៊ីវិលឱ្យមានស្ថិរភាព និងប្រសិទ្ធភាព ក្រសួងមុខងារសាធារណៈសូមជម្រាបជូនអំពីការពិនិត្យសំណើសុំផ្ទេរ និងផ្លាស់ប្ដូរកន្លែងការងាររបស់មន្ត្រីរាជការស៊ីវិលរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដូចខាងក្រោម៖

១. ក្រសួងមុខងារសាធារណៈនឹងបន្តពិនិត្យ និងផ្ដល់ទិដ្ឋាការចំពោះសំណើដែលមានការឯកភាពរួចហើយពីថ្នាក់ដឹកនាំក្រសួង ស្ថាប័នក្នុងអាណត្តិមុន អនុលោមបែបបទ និងនីតិវិធីជាធរមាន។ ដោយឡែក សំណើដែលទទួលបានការឯកភាពពីថ្នាក់ដឹកនាំនៃក្រសួង ស្ថាប័ននៅក្នុងអាណត្តិរាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា នឹងត្រូវអនុវត្តផ្អែកលើគោលការណ៍សម្រេចផ្អាកជាទូទៅរបស់រាជរដ្ឋាភិបាល រហូតដល់មានការណែនាំជាថ្មី ឬការសម្រេចដោយឡែករបស់រាជរដ្ឋាភិបាល។

២. ក្រសួងមុខងារសាធារណៈនឹងពិនិត្យ និងផ្ដល់ទិដ្ឋាការចំពោះសំណើផ្ទេរនិងផ្លាស់ប្ដូរការងារក្នុងករណីដូចខាងក្រោម៖

- មន្ត្រីរាជការកំពុងបម្រើការងារក្នុងក្រសួង ស្ថាប័នមួយហើយបានប្រឡងជាប់ក្នុងក្របខ័ណ្ឌក្រសួង ស្ថាប័នមួយផ្សេងទៀត ដែលត្រូវផ្ទេរក្របខ័ណ្ឌទៅបម្រើការងារក្នុងក្របខ័ណ្ឌក្រសួង ស្ថាប័នដែលសាមីមន្ត្រីបានប្រឡងជាប់
- មន្ត្រីរាជការដែលត្រូវបានតែងតាំងក្នុងមុខតំណែងនយោបាយដូចជា រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ និងមន្ត្រីខុទ្ទកាល័យរបស់ថ្នាក់ដឹកនាំកម្រិតនយោបាយ និងក្នុងមុខតំណែងមុខងារសាធារណៈ ជាអភិបាលនៃគណៈអភិបាលខេត្ត អភិបាលរងខេត្ត ក្រុង ស្រុក ខណ្ឌ ឬមុខតំណែងប្រហាក់ប្រហែលផ្សេងទៀត ដែលត្រូវផ្ទេរក្របខ័ណ្ឌ និងការបើកបៀវត្សនៅក្រសួង ស្ថាប័ន និងអង្គភាពថ្មី



ផ្លូវវិថីអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

- ការផ្ទេរ និងផ្លាស់ប្តូរកន្លែងការងារ ក្នុងក្រសួង ស្ថាប័នតែមួយ ដែលជួយដល់ការពង្រាយមន្ត្រីទៅតំបន់ដែលកំពុងប្រឈមនឹងបញ្ហាខ្វះមន្ត្រី (តំបន់ក្រៅទីប្រជុំជន) ក្នុងរូបភាពដូចខាងក្រោម៖
  ក. ការផ្ទេរឆ្លងអង្គភាពពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិ
  ខ. ការផ្ទេរពីរាជធានី ទៅខណ្ឌ និងទៅខេត្ត
  គ. ការផ្ទេររវាងខេត្ត និងខេត្ត (មិនអនុញ្ញាតការផ្ទេរចូលរាជធានីភ្នំពេញ)
  ឃ. ការផ្ទេរពីខេត្ត ទៅ ក្រុង ស្រុក។

សេចក្តីដូចបានជម្រាបជូនខាងលើសូម **សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីនៃក្រសួង ស្ថាប័ន ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត លោក លោកស្រី អភិបាលនៃគណៈអភិបាល ក្រុង ស្រុក ខណ្ឌ** មេត្តាជ្រាប និងទទួលនូវការគោរពរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

ថ្ងៃសុក្រ ១៥កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ២០២៣

**រដ្ឋមន្ត្រី**

**ហ៊ុន_ម៉ានី**

ចម្លងជូន៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចធិបតីនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ឯកសារ កាលប្បវត្តិ